ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងមហាផ្ទៃ មកជាអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមអ្នកច្បាប់និងនាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងអាស៊ាន ចំណុះក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០២ ស្តីពីការបង្កើតអគ្គស្នងការដ្ឋាននគរបាលជាតិ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.-**

ត្រូវបានកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងមហាផ្ទៃ មកជាអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ដែលមានខុទ្ទកាល័យរដ្ឋមន្ត្រី និងនាយកដ្ឋានបីចំណុះដូចខាងក្រោម :

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ាន
- នាយកដ្ឋានកិច្ចការរដ្ឋបាល
- នាយកដ្ឋានសរុប និងស្ថិតិ

**មាត្រា២.-**

ខុទ្ទកាល័យរដ្ឋមន្ត្រីមានភារកិច្ចដូចមានចែងក្នុងមាត្រា១៧ ជំពូកទី៦ នៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

**មាត្រា៣.-**

រក្សារចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ានដូចមានចែងក្នុងអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០០ នៅដដែល ។

**មាត្រា៤.-**

នាយកដ្ឋានកិច្ចការរដ្ឋបាល មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- សំរបសំរួលសកម្មភាពការងាររដ្ឋបាលរបស់ក្រសួង ជាមួយអង្គភាពចំណុះក្រសួង ។
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងចាត់ចែងការការពារសន្តិសុខក្នុងទីស្តីការក្រសួង ។
- សហការរៀបចំការប្រជុំ សន្និបាត សន្និសីទ សិក្ខាសាលា និងពិធីបុណ្យផ្សេងៗរបស់ក្រសួង ។
- រៀបចំ តុបតែង ថែទាំ គ្រប់គ្រងទីស្តីការក្រសួង ។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ និងធ្វើការបែងចែកសំភារៈ ថវិកា របស់អគ្គលេខាធិការ-ដ្ឋាន ក្រសួង ដល់អង្គភាពក្រោមឱវាទ ។
- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការស៊ីវិល និងនគរបាល ចំណុះអគ្គលេខាធិការដ្ឋានក្រសួង ។
- ធ្វើការងារផ្សេងៗ ទៀត ដែលថ្នាក់ដឹកនាំក្រសួង ឬ អគ្គលេខាធិការដ្ឋានប្រគល់អោយ ។

**មាត្រា៥.-**

នាយកដ្ឋានកិច្ចការរដ្ឋបាលត្រូវបានដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ ។

**មាត្រា៦.-**

នាយកដ្ឋានសរុប និងស្ថិតិមានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

-រៀបចំចាត់ចែងធ្វើរបាយការណ៍បូកសរុបសកម្មភាពការងារ និងលើកទិសដៅការងាររួមប្រចាំអឌ្ឍមាស ខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំរបស់ក្រសួង ។

-រៀបចំកសាងស្ថិតិ សន្ទស្សន៍ការងារសំខាន់ៗ និងចងក្រងឯកសារនានា សំរាប់បំរើការធ្វើសន្និបាត និងកិច្ចប្រជុំសំខាន់ៗផ្សេងទៀត របស់ក្រសួង ។

-ទំនាក់ទំនង និងសហការជាមួយក្រសួងស្ថាប័ន អង្គការសង្គមនានា អង្គភាពចំណុះក្រសួង ខេត្ត ក្រុង ដើម្បីក្តាប់ និងប្រមូលសភាពការណ៍ជាក់ស្តែង ដែលពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់ក្រសួង ។

-ពិនិត្យតាមដានការអនុវត្តនូវរាល់បទបញ្ជា សារាចរ សេចក្តីណែនាំ...របស់ក្រសួង ។

-សរុបពត៌មាន អត្ថបទពត៌មាន ដែលពាក់ព័ន្ធដល់សមត្ថកិច្ចរបស់ក្រសួង ។

**មាត្រា៧.-**

នាយកដ្ឋានសរុប និងស្ថិតិ ត្រូវបានដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអនុប្រធាននាយកដ្ឋានមួយចំនួនជា ជំនួយការ ។

**មាត្រា៨.-**

ការរៀបចំតួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ការិយាល័យនីមួយៗ ចំណុះនាយកដ្ឋានកិច្ចការរដ្ឋបាល និងនាយកដ្ឋានសរុប និងស្ថិតិ ត្រូវកំណត់ដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង** **យូ ហុកគ្រី**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី

" ដើម្បីជូនជ្រាប " ។

-ដូចមាត្រា ១០ "*ដើម្បីអនុវត្ត*" ។

-ឯកសារ កាលប្បវត្តិ ។

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥០ អនក្រ.បក
ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០០២

## អង្គការលេខ ១ របស់អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ

